**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ៧១០ ហិកតា កាត់ចេញពីដីអតីតសហគ្រាសសេរី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដែលទំហំ ៦២៥ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៨៥ ហិកតា រក្សាទុកជាដីសហគមន៍ព្រៃឈើ និងជាដីសាធារណៈរបស់រដ្ឋ នៅភូមិក្រាំងលាវ ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦២៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិក្រាំងលាវ ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកជាដីសហគមន៍ព្រៃឈើ និងបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៣១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

**សម្រេច**

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម។

**មាត្រា ២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចខាងក្រោម ៖

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់ក្រសួងពាណិជ្ជកម្ម
- រៀបចំមុខងារនិងភារកិច្ចអង្គភាពនានានៃក្រសួងពាណិជ្ជកម្ម
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ក្នុងវិស័យពាណិជ្ជកម្ម។

**មាត្រា ៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពនៃក្រសួងពាណិជ្ជកម្ម ទាំងនៅថ្នាក់កណ្តាល នៅមូលដ្ឋាននិងសហគ្រាសសាធារណៈ ដោយគ្របដណ្តប់លើវិស័យពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ៤ .-**

ក្រសួងពាណិជ្ជកម្ម បំពេញមុខងារជាសេនាធិការឲ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

បេសកកម្មនេះ ត្រូវធ្វើឡើងតាមរយៈការរៀបចំ និងការអនុវត្តឲ្យបានត្រឹមត្រូវនូវគោលនយោបាយ ក្របខណ្ឌច្បាប់ និងបទបញ្ញាទាំងឡាយដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម។

**មាត្រា ៥ .-**

ក្រសួងពាណិជ្ជកម្ម មានមុខងារ និងភារកិច្ច ដូចតទៅ៖

- រួមចំណែកកសាងគោលនយោបាយពាណិជ្ជកម្ម ដោយឈរលើមូលដ្ឋានច្បាប់ បទប្បញ្ញត្តិជាតិ និងអន្តរជាតិ
- កំណត់អំពីសន្និធិទំនិញយុទ្ធសាស្ត្រ
- រក្សាស្ថិរភាពថ្លៃទំនិញនៅលើទីផ្សារ និងធ្វើកិច្ចអន្តរាគមន៍លើទីផ្សារ ពិសេសចំពោះមុខទំនិញជាយុទ្ធសាស្ត្រ
- ស្រាវជ្រាវ និងអភិវឌ្ឍទីផ្សារ
- ជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្មតាមរយៈការធ្វើពិពិធកម្មទីផ្សារ និងទំនិញនាំចេញ និងការបង្កើនល្បឿនសមាហរណកម្មទៅក្នុងក្របខ័ណ្ឌពាណិជ្ជកម្មសេរីសំខាន់ៗក្នុងតំបន់ និងពិភពលោក
- រៀបចំ ដឹកនាំ ត្រួតពិនិត្យពាណិជ្ជកម្មក្រៅប្រទេស ផ្តល់អជ្ញាប័ណ្ណ និងវិញ្ញាបនបត្រសម្រាប់ការនាំចេញនាំចូលទំនិញតាមច្បាប់ និងបទប្បញ្ញត្តិ
- អនុវត្តនយោបាយ ដើម្បីអភិវឌ្ឍវិស័យឯកជន ធានាសេរីភាព និងសមធម៌នៃការធ្វើពាណិជ្ជកម្ម
- រៀបចំគោលនយោបាយប្រកួតប្រជែង
- តាក់តែងច្បាប់ពាណិជ្ជកម្ម បទប្បញ្ញត្តិពាណិជ្ជកម្ម និងគ្រប់គ្រងមជ្ឈមណ្ឌលតម្កល់ឯកសារ និងព័ត៌មានពាណិជ្ជកម្ម
- គាំទ្រដល់មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- អភិវឌ្ឍវិស័យពាណិជ្ជកម្ម និងវិស័យពាក់ព័ន្ធ តាមរយៈអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម
- គ្រប់គ្រងការតម្កល់លិខិតជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានា
- រៀបចំ ចូលរួមនិងគ្រប់គ្រងពិព័រណ៍ពាណិជ្ជកម្មជាតិ និងអន្តរជាតិ
- បំពេញកាតព្វកិច្ចជាសមាជិកការិយាល័យពិព័រណ៍អន្តរជាតិ(BIE) និងកិច្ចការពិព័រណ៍ពិភពលោក
- ជំរុញឲ្យមានគុណភាពជញ្ជីងពាណិជ្ជកម្ម
- ផ្សព្វផ្សាយ និងធ្វើទំនាក់ទំនងជាមួយទីផ្សារអន្តរជាតិសំដៅអភិវឌ្ឍផលិតផលកម្ពុជា
- សិក្សាស្រាវជ្រាវស្ថានភាពសេដ្ឋកិច្ចជាតិ និងអន្តរជាតិ ព្រមទាំងព្យាករណ៍និន្នាការទីផ្សារសម្រាប់ផ្សព្វផ្សាយដល់ផលិតករ និងពាណិជ្ជករ
- សម្របសម្រួលការងារកម្មសិទ្ធិបញ្ញា និងជាលេខាធិការដ្ឋាននៃគណកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា
- គ្រប់គ្រងម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពីចរិកលក្ខណៈនៃទំនិញ និងសេវា និងការការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្ម

- ចលនា និងផ្សព្វផ្សាយការប្រើប្រាស់ផលិតផលទំនិញនិងសេវា និងចាត់វិធានការការពារផលប្រយោជន៍ជូនអ្នកប្រើប្រាស់
- ត្រួតពិនិត្យគុណភាព សុវត្ថិភាពលើផលិតផលទំនិញនាំចេញ នាំចូលរួមជាមួយស្ថាប័នពាក់ព័ន្ធ
- បង្ក្រាបការក្លែងបន្លំផ្នែកពាណិជ្ជកម្មនៅលើទីផ្សារ រួមទាំងការតាំងពិព័រណ៍ និងការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញ និងសេវា
- សម្របសម្រួលកិច្ចការត្រួតពិនិត្យ គុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវារវាងស្ថាប័នពាក់ព័ន្ធ និងសកម្មភាពការងាររបស់ភ្នាក់ងារ
- ផ្តល់សេវាត្រួតពិនិត្យពាណិជ្ជកម្មក្នុងនាមភាគីទី៣ ជូនការីសេដ្ឋកិច្ច
- គ្រប់គ្រង និងអនុវត្តបទប្បញ្ញត្តិនៃប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនានា និងភាពអនុគ្រោះក្រោមតំបន់ពាណិជ្ជកម្មសេរី និងទ្វេភាគី ព្រមទាំងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ
- ធ្វើជាអាណាព្យាបាលបច្ចេកទេសសភាពាណិជ្ជកម្ម និងសមាគមពាណិជ្ជកម្ម
- ធ្វើសហប្រតិបត្តិការនិងធ្វើសមាហរណកម្មសេដ្ឋកិច្ចពាណិជ្ជកម្មជាមួយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជាមួយបណ្តាប្រទេស ព្រមទាំងអង្គការអន្តរជាតិនានា
- គ្រប់គ្រង កាន់កាប់ការចុះបញ្ជីពាណិជ្ជកម្ម និងតាមដានសកម្មភាពពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- អភិវឌ្ឍការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច
- អភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងពាណិជ្ជកម្ម

**មាត្រា ៦ .–**

ក្រសួងពាណិជ្ជកម្ម មានរចនាសម្ព័ន្ធដូចខាងក្រោម៖

ក.អង្គភាពថ្នាក់ជាតិ

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
- អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
- អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម
- អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម
- អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល)
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង

ខ.សហគ្រាសសាធារណៈ

- ក្រុមហ៊ុនហ្វ្រីនគ្រេដ

គ.អង្គភាពថ្នាក់មូលដ្ឋាន៖

នៅថ្នាក់ក្រោមជាតិមានមន្ទីរពាណិជ្ជកម្ម សាខាកាំកុងត្រូល និងសាខាសមត្ថកិច្ចជំនាញរាជធានីខេត្ត ។

**មាត្រា ៧ .–**

អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជាជំនួយការ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអគ្គាធិការរងមួយចំនួនឋានៈស្មើអគ្គនាយករង ជាជំនួយការ។

នាយកដ្ឋានដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដឹកនាំដោយប្រធានមន្ទីរមួយរូបឋានៈស្មើអនុប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមន្ទីរមួយចំនួន។

តំណាងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស មានប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន អមដោយមន្ត្រីមួយចំនួនជាជំនួយការតាមការចាំបាច់។

សាខាកាំកុងត្រូលរាជធានី ខេត្ត មជ្ឈមណ្ឌលត្រួតពិនិត្យ និងផែស្ងួត ដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើប្រធានការិយាល័យ និងអមដោយអនុប្រធានមួយចំនួន។

អង្គការលេខរបស់ក្រសួងពាណិជ្ជកម្ម ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៨ .-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន វិទ្យាស្ថាន និងអង្គភាពនានាក្រោមឱវាទរបស់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពមូលដ្ឋាននៃក្រសួងពាណិជ្ជកម្ម ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

## ជំពូកទី ៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ៩ .-**

ខុទ្ទកាល័យក្រសួងពាណិជ្ជកម្មទទួលបន្ទុកបេសកកម្មទាំងឡាយដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី ៤
## អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**មាត្រា ១០ .-**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលរបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពថ្នាក់មូលដ្ឋានក្រោមឱវាទ និងអង្គភាពដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួង
- រៀបចំ និងគ្រប់គ្រងរាល់ការងារទាក់ទងនឹងមន្ត្រីរាជការ
- លើកគម្រោងរៀបចំ និងគ្រប់គ្រងរាល់ការងារទាក់ទងថវិកា គណនេយ្យ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ក្រសួង
- ចូលរួមរៀបចំលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

**មាត្រា ១១ .-**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាននាយកដ្ឋានចំណុះចំនួន ៣(បី) ដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានបុគ្គលិក

- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

**មាត្រា ១២ .-**

នាយកដ្ឋានរដ្ឋបាល បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ លើការងាររដ្ឋបាល។

នាយកដ្ឋានបុគ្គលិក បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ លើការងារបុគ្គលិក។

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ លើការងារគណនេយ្យ និងហិរញ្ញវត្ថុ។

## ជំពូកទី ៥

## អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ

**មាត្រា ១៣ .-**

អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- ធ្វើសហប្រតិបត្តិការ និងធ្វើសមាហរណកម្មសេដ្ឋកិច្ចពាណិជ្ជកម្ម ជាមួយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជាមួយបណ្តាប្រទេសក្នុងទ្វីបនានា
- ធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិនានា
- ប្រតិបត្តិរាល់នយោបាយ និងបេសកកម្មរបស់ក្រសួង ក្នុងការគ្រប់គ្រង ដឹកនាំការងារពាណិជ្ជកម្មអន្តរជាតិ
- ស្រាវជ្រាវ និងរៀបចំគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស ឲ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ទទួលបន្ទុកការងារសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មក្នុងក្របខ័ណ្ឌអនុតំបន់ ក្របខ័ណ្ឌតំបន់ និងក្របខ័ណ្ឌពិភពលោក
- រៀបចំឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្មសម្រាប់ធ្វើជាមូលដ្ឋាននៃការចរចាបើកច្រកទីផ្សារ
- រៀបចំធ្វើសន្ទស្សន៍សេដ្ឋកិច្ច និងវិភាគលើស្ថានភាពពាណិជ្ជកម្មអន្តរជាតិ
- សម្របសម្រួលជំនួយទាក់ទងនឹងពាណិជ្ជកម្មជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិ
- សម្របសម្រួល និងជំរុញការអនុវត្តកាតព្វកិច្ចរបស់កម្ពុជា ដែលបានសន្យាជាមួយអង្គការពាណិជ្ជកម្មពិភពលោក ជាមួយអាស៊ាន និងក្នុងក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរីដទៃទៀត
- ជំរុញវិស័យពាណិជ្ជកម្ម និងវិស័យពាក់ព័ន្ធ តាមរយៈការរៀបចំអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មទាំងមូល
- ធ្វើសហប្រតិបត្តិការជាមួយបណ្តាប្រទេស និងសហគមន៍ដៃគូអភិវឌ្ឍន៍ ដើម្បីរកឱកាសសម្រាប់បណ្តុះបណ្តាលធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន
- ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់បទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានារបស់កម្ពុជាដែលទាក់ទងនឹងកិច្ចព្រមព្រៀង សន្ធិសញ្ញាពាណិជ្ជកម្មតំបន់ និងពិភពលោកដែលកម្ពុជាជាសមាជិកហត្ថលេខី ដើម្បីធានានូវអនុលោមភាព

- ជាមជ្ឈមណ្ឌលសម្របសម្រួលសម្រាប់ទទួល និងផ្តល់ព័ត៌មានទាក់ទងនឹងវិស័យសេវាកម្ម វិស័យពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀតរបស់ព្រះរាជាណាចក្រកម្ពុជា
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

**មាត្រា ១៤ .-**

អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ មាននាយកដ្ឋានចំណុះចំនួន ៥(ប្រាំ) ដូចខាងក្រោម៖

- នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក
- នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- នាយកដ្ឋានអាមេរិក
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- នាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់

**មាត្រា ១៥ .-**

នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ លើការងារពាក់ព័ន្ធជាមួយទ្វីបអាស៊ីប៉ាស៊ីហ្វិក។

នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ លើការងារពាក់ព័ន្ធជាមួយទ្វីបអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក។

នាយកដ្ឋានអាមេរិក បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ លើការងារពាក់ព័ន្ធជាមួយទ្វីបអាមេរិក។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ លើការងារសហប្រតិបត្តិការអន្តរជាតិ។

នាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ លើការងារផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ដែលពាក់ព័ន្ធជាមួយអង្គការពាណិជ្ជកម្មពិភពលោក។

## ជំពូកទី ៦
## អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

**មាត្រា ១៦ .-**

អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- អនុវត្តរាល់សកម្មភាពរបស់ក្រសួង លើគោលនយោបាយគ្រប់គ្រង ដឹកនាំពាណិជ្ជកម្មក្នុងប្រទេស
- កំណត់អំពីសន្និធិទំនិញយុទ្ធសាស្ត្រ
- តាមដានថ្លៃទំនិញ និងដំណើរការទីផ្សារ
- គ្រប់គ្រងប្រព័ន្ធព័ត៌មានទីផ្សារ(EMCS)
- ធានាសេរីភាព និងការធ្វើពាណិជ្ជកម្មប្រកបដោយសមធម៌របស់ផ្នែកឯកជន ក្នុងសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្ម
- ធ្វើជាអាណាព្យាបាលបច្ចេកទេសសភាពាណិជ្ជកម្ម និងសមាគមពាណិជ្ជកម្ម
- ជួយរៀបចំសភាពាណិជ្ជកម្ម និងជួយណែនាំលើកិច្ចការច្បាប់ និងបច្ចេកទេសទាក់ទងនឹងគោលនយោបាយពាណិជ្ជកម្ម និងសេដ្ឋកិច្ច
- ជួយចាត់ចែងកិច្ចសម្រួលពាណិជ្ជកម្ម

- គ្រប់គ្រងទីផ្សារ និងអនុវត្តគោលនយោបាយពាណិជ្ជកម្មក្នុងស្រុក ដូចជាបិទស្លាកថ្លៃទំនិញ ត្រួតពិនិត្យស្តុកទំនិញយុទ្ធសាស្ត្រ និងទំនិញចាំបាច់តាមការកំណត់របស់រាជរដ្ឋាភិបាល
- តាមដានការងារដែលក្រសួងបានធ្វើប្រតិភូកម្មទៅមន្ទីរពាណិជ្ជកម្មរាជធានីខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- លើកវិធានការទប់ស្កាត់ការលក់បង្ខូចថ្លៃ ការលក់ផ្តួប ការលក់បោកបញ្ឆោតអតិថិជន
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញចលនាភូមិមួយផលិតផលមួយ
- ចាត់ចែង តាក់តែងច្បាប់ពាណិជ្ជកម្ម បទប្បញ្ញត្តិពាណិជ្ជកម្ម និងគ្រប់គ្រងមជ្ឈមណ្ឌលតម្កល់ឯកសារ និងព័ត៌មានពាណិជ្ជកម្ម
- គាំទ្រដល់មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- គ្រប់គ្រង ការតម្កល់លិខិតជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានា
- រៀបចំ និងគ្រប់គ្រងបណ្តាញព័ត៌មានវិទ្យា និងគេហទំព័ររបស់ក្រសួង
- អភិវឌ្ឍការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច
- រៀបចំធ្វើសន្ទស្សន៍ថ្លៃទំនិញចាំបាច់សំខាន់ៗ និងធ្វើស្ថិតិពាណិជ្ជកម្ម
- សិក្សាស្រាវជ្រាវប្រមូល និងវិភាគព័ត៌មានដើម្បីបង្កើតតារាងប្រែប្រួលថ្លៃ
- ទទួលជាមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មរបស់ក្រសួង
- កសាងផែនការយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់ក្រសួង
- កសាងផែនការ និងរៀបចំកម្មវិធីសិក្សាលើគ្រប់មុខជំនាញពាក់ព័ន្ធនឹងការងារពាណិជ្ជកម្ម និងសេដ្ឋកិច្ចដើម្បីធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ទាំងរយៈពេលខ្លី មធ្យម និងរយៈពេលវែង
- ធ្វើជាយន្តការអនុវត្តការងារបណ្តុះបណ្តាល បំប៉នចំណេះដឹងដល់មន្ត្រីរាជការនៃស្ថាប័ន អង្គភាពសាធារណៈ និងបុគ្គលិក មកពីវិស័យឯកជន ឬសិស្ស និស្សិតទូទៅ ទៅតាមកម្មវិធីសិក្សា និងតាមតម្រូវការចាំបាច់
- អនុវត្តកិច្ចសហប្រតិបត្តិការ សម្របសម្រួលក្នុងការបើកវគ្គបណ្តុះបណ្តាលនានា ក្រោមគម្រោងជំនួយគាំទ្រពីដៃគូអភិវឌ្ឍន៍នានា ឬពីអង្គការជាតិ និងអន្តរជាតិ
- រៀបចំការស្រាវជ្រាវ វិភាគ ឃ្លាំមើលទីផ្សារ និងលំហូរផលិតផលកម្ពុជា
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

**មាត្រា ១៧ .-**

អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស មាននាយកដ្ឋានចំណុះចំនួន ៤(បួន) ដូចខាងក្រោម៖

- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន
- នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម
- វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ

**មាត្រា ១៨ .-**

នាយកដ្ឋាននីតិកម្ម បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស លើការងារនីតិកម្ម។

នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស លើការងារអភិវឌ្ឍវិស័យឯកជន។

នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស លើការងារផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម។

វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស លើការងារបណ្តុះបណ្តាលពាក់ព័ន្ធជាមួយវិស័យពាណិជ្ជកម្ម និងស្រាវជ្រាវ។

## ជំពូកទី ៧
## អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម

**មាត្រា ១៩ ._**

អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្មមានភារកិច្ចដូចតទៅ៖

- អនុវត្តរាល់សកម្មភាពរបស់ក្រសួង លើគោលនយោបាយគ្រប់គ្រង និងផ្តល់សេវាពាណិជ្ជកម្ម
- ស្រាវជ្រាវ និងរៀបចំគោលនយោបាយសេវាពាណិជ្ជកម្ម
- រៀបចំ និងអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការផ្តល់សេវាពាណិជ្ជកម្មឲ្យមានប្រសិទ្ធភាពខ្ពស់
- គ្រប់គ្រង កាន់កាប់ការចុះបញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងតាមដានសកម្មភាពពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- ផ្តល់សេវាពិនិត្យ និងរក្សាទុកការអនុញ្ញាតឲ្យប្រើប្រាស់នាមករក្រុមហ៊ុន សហគ្រាស
- ផ្តល់សេវាប្រឹក្សាយោបល់ទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម និងផ្តល់ព័ត៌មានពាក់ព័ន្ធ
- គ្រប់គ្រងការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុកឯកសារ ការរក្សាទុកព័ត៌មាន ទិន្នន័យសហគ្រាសក្រុមហ៊ុន
- ជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញាកម្ពុជា
- ទទួលបន្ទុក និងសហការរៀបចំច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងកម្មសិទ្ធិបញ្ញា
- សម្របសម្រួលការងារកម្មសិទ្ធិបញ្ញា គ្រប់គ្រងដោយផ្ទាល់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ម៉ាកការសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពីចរិកលក្ខណៈនៃទំនិញ និងសេវា និងការការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្ម
- ជាអង្គភាពសម្របសម្រួលកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគីលើវិស័យកម្មសិទ្ធិបញ្ញាជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិនានា
- សហការជាមួយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នតុលាការដើម្បីបញ្ឈប់ការរំលោភបំពានកម្មសិទ្ធិបញ្ញា ដោះស្រាយវិវាទនានាទាក់ទងនឹងកម្មសិទ្ធិបញ្ញាដែលជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម
- ជំរុញការធ្វើពាណិជ្ជកម្មកម្មសិទ្ធិបញ្ញា និងការវាយតម្លៃទ្រព្យកម្មសិទ្ធិបញ្ញា
- គ្រប់គ្រង និងអនុវត្តបទប្បញ្ញត្តិ នៃប្រព័ន្ធអនុគ្រោះទូទៅ និងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនានាព្រមទាំងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ
- រៀបចំ និងអនុវត្តលិខិតបទដ្ឋានបច្ចេកទេស និងច្បាប់ទាក់ទងនឹងវិធានប្រភពដើមទំនិញ ក្រោមក្របខ័ណ្ឌប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងតំបន់ពាណិជ្ជកម្មសេរីនានា
- រៀបចំ និងពិនិត្យឯកសារចេញវិញ្ញាបនបត្រប្រភពដើមទំនិញ សម្រាប់ការនាំចេញទំនិញ ទៅកាន់ប្រទេសអាស៊ាន និងប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជា
- គ្រប់គ្រងការចេញវិញ្ញាបនបត្របញ្ជាក់អត្តសញ្ញាណផលិតផល Halal

- គ្រប់គ្រងការចេញវិញ្ញាបនបត្រត្បូងពេជ្រមិនទាន់កែច្នៃក្រោមការអនុវត្តគម្រោងគីមប័រលីប្រូសេស (Kimberly Process)
- ទទួលបន្ទុកជាអង្គភាពសម្របសម្រួលក្នុងនាមកម្ពុជាជាសមាជិកនៃអង្គការគីមប័រលី
- គ្រប់គ្រងការនាំចូលថ្នាំងក្រណាត់ចាក់
- ចេញអាជ្ញាប័ណ្ណនាំចេញ នាំចូលទំនិញផ្អែកតាមច្បាប់ បទប្បញ្ញត្តិ និងតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

**មាត្រា ២០ .-**

អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម មាននាយកដ្ឋានចំណុះចំនួន ៣(បី) និងមានតំណាងពាណិជ្ជកម្មតំបន់សេដ្ឋកិច្ចពិសេស ជាអង្គភាពមូលដ្ឋានដូចខាងក្រោម៖

- នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- នាយកដ្ឋានកម្មសិទ្ធិបញ្ញា
- នាយកដ្ឋាននាំចេញ នាំចូល
- តំណាងពាណិជ្ជកម្មតំបន់សេដ្ឋកិច្ចពិសេស

**មាត្រា ២១ .-**

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម លើការងារចុះបញ្ជីពាណិជ្ជកម្ម។

នាយកដ្ឋានកម្មសិទ្ធិបញ្ញា បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម លើការងារកម្មសិទ្ធិបញ្ញា។

នាយកដ្ឋាននាំចេញ នាំចូល បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម លើការងារនាំចេញ នាំចូល។

តំណាងពាណិជ្ជកម្មតំបន់សេដ្ឋកិច្ចពិសេស បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម លើការងាររៀបចំ ពិនិត្យឯកសារ និងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញនៅរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស។

## ជំពូកទី ៨
## អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

**មាត្រា ២២ .-**

អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- ជួយរកទីផ្សារជូនកសិករ និងពាណិជ្ជករ
- ស្រាវជ្រាវ និងអភិវឌ្ឍទីផ្សារ
- រៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មក្នុង និងក្រៅប្រទេសព្រមទាំងធ្វើការណែនាំ និងលើកទឹកចិត្តដល់ការចូលរួមរបស់ផលិតករ និងរោងជីវករជាតិនៅក្នុងកម្មវិធីពិព័រណ៍ក្រៅប្រទេស
- គ្រប់គ្រងមជ្ឈមណ្ឌលពិព័រណ៍ពាណិជ្ជកម្មជាតិខេត្ត ក្រុង និងតំបន់
- សម្របសម្រួលលើកទឹកចិត្ត គ្រប់គ្រង និងចេញលិខិតអនុញ្ញាតដល់ការរៀបចំពិព័រណ៍ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ដែលរៀបចំដោយក្រុមហ៊ុនក្នុងស្រុក ក្រុមហ៊ុនបរទេស និងស្ថាប័ននានា

- ទទួលបន្ទុកជាចំណុចប្រសព្វ សម្រាប់ការងារការិយាល័យព័ត៌មានអន្តរជាតិ (BIE) និងការងារជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការអន្តរក្រសួង ដើម្បីរៀបចំចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ
- រៀបចំយុទ្ធសាស្ត្រស្វែងរកទីផ្សារ ស្រាវជ្រាវវិភាគ និងកសាងគោលនយោបាយទីផ្សារនិងជំរុញការនាំចេញ
- រៀបចំ និងទទួលបេសកកម្មពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ក្នុងបំណងបង្កើតនូវវេទិកាដៃគូពាណិជ្ជកម្ម ឬជំនួបពាណិជ្ជកម្ម សម្រាប់ពាណិជ្ជកម្មក្នុង និងក្រៅប្រទេសដោយសហការជាមួយអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
- សិក្សាស្រាវជ្រាវ និងវិភាគសកម្មភាពពាណិជ្ជកម្មនៅកម្ពុជា ព្រមទាំងផ្តួចផ្តើមគំនិតបង្កើតគោលនយោបាយជូនរាជរដ្ឋាភិបាល
- សហប្រតិបត្តិការជាមួយដៃគូជំរុញពាណិជ្ជកម្ម និងមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោក រួមមានមជ្ឈមណ្ឌលពាណិជ្ជកម្មអាស៊ាន-ជប៉ុន មជ្ឈមណ្ឌលពាណិជ្ជកម្មអាស៊ាន-ចិន មជ្ឈមណ្ឌលពាណិជ្ជកម្មអាស៊ាន-កូរ៉េ។ល។
- រៀបចំ និងចាត់ចែងសិក្ខាសាលា សន្និសីទ វេទិកាពាណិជ្ជកម្ម និងកិច្ចប្រជុំស្តីពីការជំរុញពាណិជ្ជកម្ម សម្រាប់បង្កើតឲ្យមានដៃគូពាណិជ្ជកម្ម
- ចូលរួមកសាង និងអនុវត្តគោលនយោបាយផលិតផលជាតិ ក្នុងគោលដៅបម្រើទីផ្សារក្នុងស្រុក និងនាំចេញ
- ចូលរួមអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ជាមួយស្ថាប័នពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវលើផលិតផលថ្មីៗ និងការអភិវឌ្ឍន៍ផលិតផលដែលជាសក្តានុពលសម្រាប់បម្រើទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ
- ធ្វើជាអ្នកពិគ្រោះយោបល់ និងប្រឹក្សាលើកិច្ចការទីផ្សារ និងពាណិជ្ជកម្ម
- ផ្សព្វផ្សាយព័ត៌មានដែលទាក់ទងជាមួយការងារជំរុញពាណិជ្ជកម្ម និងទីផ្សារក្រៅប្រទេស
- ផ្សព្វផ្សាយ និងធ្វើទំនាក់ទំនងជាមួយទីផ្សារអន្តរជាតិ តាមរយៈការដាក់តំណាងពាណិជ្ជកម្ម
- គ្រប់គ្រងមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មក្នុង និងក្រៅប្រទេស
- រៀបចំ និងគ្រប់គ្រងគេហទំព័រសម្រាប់ជំរុញពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

**មាត្រា ២៣ .-**

អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម មាននាយកដ្ឋានចំណុះចំនួន ៣(បី) ដូចខាងក្រោម៖

- នាយកដ្ឋានកិច្ចការព័ត៌មាន
- នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ
- នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

និងមានតំណាងពាណិជ្ជកម្ម (ទីប្រឹក្សា និងអនុព័ន្ធពាណិជ្ជកម្ម) ប្រចាំការនៅក្រៅប្រទេស។

**មាត្រា ២៤ .-**

នាយកដ្ឋានកិច្ចការព័ត៌មានបំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មលើការងារកិច្ចការព័ត៌មាន។

នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មលើការងារអភិវឌ្ឍន៍ទីផ្សារ។

នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម បំពេញមុខងារជាសេនាធិការឲ្យ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម លើការងារជំរុញការអនុវត្តន៍ កែលម្អ និងអភិវឌ្ឍគោលនយោបាយពាណិជ្ជកម្ម។

តំណាងពាណិជ្ជកម្មក្រៅប្រទេស បំពេញមុខងារធ្វើទំនាក់ទំនង ផ្សព្វផ្សាយ និងផ្តល់ព័ត៌មាន ពាក់ព័ន្ធការងារសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗជាមួយព្រះរាជាណាចក្រកម្ពុជា អមស្ថានឯកអគ្គរាជទូតកម្ពុជា។

## ជំពូកទី ៩
## អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហារ័ណ អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល)

**មាត្រា ២៥ .-**

អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហារ័ណ អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) បំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋាន កម្ពុជាត្រួតពិនិត្យទំនិញនីហារ័ណ អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) ឲ្យទៅជាអគ្គនាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញ នីហារ័ណ អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម។

## ជំពូកទី ១០
## អគ្គាធិការដ្ឋាន

**មាត្រា ២៦ .-**

អគ្គាធិការដ្ឋានបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- ធ្វើអធិការកិច្ចលើដំណើរការរដ្ឋបាលរបស់ក្រសួង អង្គភាពក្រោមឱវាទ សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងវិស័យពាណិជ្ជកម្ម
- ធ្វើការតាមដាន និងពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិនានា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់មន្ត្រីដែលកំពុងគ្រប់គ្រងលើវិស័យពាណិជ្ជកម្មឲ្យទទួលខុសត្រូវតាមវិធានការ វិន័យរដ្ឋបាល និងតុលាការ
- ចុះត្រួតពិនិត្យពាក្យបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋ សង្គមស៊ីវិលដែលទាក់ទងការគ្រប់គ្រងវិស័យពាណិជ្ជកម្ម
- ធ្វើអធិការកិច្ចលើវិវាទពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

## ជំពូកទី ១១
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា ២៧ .-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ៤០អនក្រ.បក ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។

## ជំពូកទី ១២
## អង្គភាពថ្នាក់ក្រោមជាតិនៃក្រសួងពាណិជ្ជកម្ម

**មាត្រា ២៨ ._**

ក្រសួងពាណិជ្ជកម្មមានអង្គភាពថ្នាក់ក្រោមជាតិដែលជាមន្ទីរពាណិជ្ជកម្មរាជធានី ខេត្តដើម្បីបំពេញមុខងារពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្មនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី ១៣
## សហគ្រាសសាធារណៈ

**មាត្រា ២៩ ._**

អង្គភាពសហគ្រាសសាធារណៈជានីតិបុគ្គល ដែលទទួលបន្ទុកធ្វើការងារតាមជំនាញឯកទេសរបស់ខ្លួនស្របតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ អនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនហ្វ្រីនគ្រេជ។

## ជំពូកទី ១៤
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ៣០ ._**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមលក្ខខណ្ឌ នៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល។

## ជំពូកទី ១៥
## អន្តរប្បញ្ញត្តិ

**មាត្រា ៣១ ._**

ប្រកាសស្តីពីការបង្កើត ឬ ការរៀបចំនិងការប្រព្រឹត្តទៅការិយាល័យនានាចំណុះឲ្យអគ្គនាយកដ្ឋាន ឬអគ្គាធិការដ្ឋាន ឬនាយកដ្ឋាន ឬមជ្ឈមណ្ឌល ឬអង្គភាពនានានៃក្រសួងពាណិជ្ជកម្ម ត្រូវបន្តមានសុពលភាពអនុវត្តរហូតដល់មានប្រកាសថ្មីរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

ការរៀបចំ និងការប្រព្រឹត្តទៅថ្នាក់ក្រោមនាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី ១៦
## អវសានប្បញ្ញត្តិ

**មាត្រា ៣២ ._**

ការកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នឹងសហការណ៍ជាមួយប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីបែងចែកការទទួលខុសត្រូវ និងអនុវត្តការងារតាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងប្រធានស្ថាប័ននោះ។

**មាត្រា ៣៣ ._**

អនុក្រឹត្យនេះត្រូវជំនួសអនុក្រឹត្យដូចខាងក្រោម៖

- អនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម។

**មាត្រា ៣៤ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៥ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

**<u>កន្លែងទទួល:</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធក្រសួងពាណិជ្ជកម្ម



**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

-បានឃើអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៤រូប :

១-លោកវរសេនីយ៍ទោ **អ៊ុំ សំអឿន** អត្តលេខ ០៩៩២១

២-លោកវរសេនីយ៍ទោ **ឈុំ សារី** អត្តលេខ ៣២៣២៤

៣-លោកវរសេនីយ៍ទោ **សួន ខឿន** អត្តលេខ ៦៨២៩៨

៤-លោកវរសេនីយ៍ទោ **កៅ ប៊ុម្មុនី** អត្តលេខ ៧១៨៩៨

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ១៤ ខែ មីនា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៧៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា១.**. បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន០២រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយអភិវឌ្ឍន៍វិស័យអប់រំ ក្នុងរាជធានីភ្នំពេញ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

-លោក **ជា ជាតិ** ប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

-លោក **អ៊ុក សម្បត្តិ** ប្រធានការិយាល័យផែនការនៃមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ

**មាត្រា២.**. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៣ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ១០ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ ជួសជុលសាលារៀន ផ្លូវថ្នល់ អណ្តូងទឹក របងវត្ត និងបង្គន់អនាម័យ ស្ថិតនៅក្នុងឃុំមេបុណ្យ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៨ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **នី ធឿន** | ព្រះចៅអធិការវត្តភ្នំគង់ | បច្ច័យចំនួន ១១.០៥០ ដុល្លារ |
| ២-ព្រះតេជគុណ | **កើត សាឡុន** | ព្រះគ្រូស្តាំវត្តភ្នំគង់ | បច្ច័យចំនួន ១០.២១០ ដុល្លារ |
| ៣-ឧបាសក | **តាំង ម៉េងសុង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៦.៥០០ ដុល្លារ |
| ៤-ឧបាសិកា | **ឈុន ផា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៤.៨០០ ដុល្លារ |
| ៥-លោក | **ម៉េង អ៊ូ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៤.៥០០ ដុល្លារ |
| ៦-លោក | **ម៉េង ចំរុង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៣.៤០០ ដុល្លារ |
| ៧-លោកស្រី | **អុំ សុភ័ក្រ្តកញ្ញា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.៦០០ ដុល្លារ |
| ៨-លោក | **អ៊ុន សារ៉ាន់** | នាយកសាលាបឋមសិក្សាភ្នំគង់ | ថវិកាចំនួន ១០.៣១៥ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០២ គ្រឿង ផ្តល់ជូន :**

១-ឧបាសក **ឆេត ផែន** គណៈកម្មការវត្តភ្នំតង់ ថវិកាចំនួន ៦.១១០ ដុល្លារ

២-ឧបាសក **ទិន ហាន** គណៈកម្មការវត្តភ្នំតង់ ថវិកាចំនួន ៥.០៧៥ ដុល្លារ

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៤*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៧៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សម្រេច

**មាត្រា ១.-** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ចំនួន ៦៩៤គ្រឿង ជូនមន្ត្រីរាជការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | គុយ ម៉ារិនឌី | អនុរដ្ឋលេខាធិការ |
| ២- | ឯកឧត្តម | សៅ វណ្ណសិរីវុទ្ធ | អនុរដ្ឋលេខាធិការ |
| ៣- | ជំទាវ | ម៉ុម ថានី | អនុរដ្ឋលេខាធិការ |
| ៤- | លោក | ឈាង ជាន | អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស |
| ៥- | លោក | ឡាយ វិសិដ្ឋ | អនុប្រធានមន្ទីរកសិកម្មខេត្តពោធិ៍សាត់ |
| ៦- | លោក | ហេង ហុង | អនុប្រធានការិយាល័យផ្សព្វផ្សាយកសិកម្មនៃមន្ទីរកសិកម្មខេត្តពោធិ៍សាត់ |
| ៧- | លោក | ព្រំ វិច | ប្រធានការិយាល័យផលិតកម្មនិងបសុព្យាបាលនៃមន្ទីរកសិកម្មខេត្តសៀមរាប |
| ៨- | លោក | ឃី វិបុលបុត្រា | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ៩- | លោកស្រី | ស៊ិន កុលមណី | មន្ត្រីការិយាល័យរដ្ឋបាលនិងបុគ្គលិកនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ១០- | លោក | ឈ បៀងគង់ | អនុប្រធានការិយាល័យរដ្ឋបាល-បុគ្គលិកនៃមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ១១- | លោក | តិច ហេង | អនុប្រធានការិយាល័យផែនការ-គណនេយ្យនៃមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ១២- | លោក | សាន ស៊ីថាន | អនុប្រធានការិយាល័យផែនការ-គណនេយ្យនៃមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ១៣- | លោក | លឹម និមិត្តារ៉ា | ប្រធានការីកសិឧស្សាហកម្មនៃមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ១៤- | លោក | ហ៊ូ ឈុនអ៊ី | អនុប្រធានការិយាល័យផែនការ-គណនេយ្យនៃមន្ទីរកសិកម្មខេត្តកំពង់ធំ |

| | | | |
|---|---|---|---|
| ១៥- | លោក | គុយ ហាក់ | អនុប្រធានមន្ទីរកសិកម្មខេត្តព្រះសីហនុ |
| ១៦- | លោក | សួន កំសាន្ត | ប្រធានការិយាល័យផែនការ-គណនេយ្យនៃមន្ទីរកសិកម្មខេត្តព្រះសីហនុ |
| ១៧- | លោក | សួន វុធ | អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ |
| ១៨- | លោក | សេក ភក្តី | អនុប្រធានទទួលបន្ទុករួមនាយកដ្ឋានរដ្ឋបាលនិងនីតិកម្មនៃអគ្គនាយកដ្ឋានកៅស៊ូ |
| ១៩- | លោក | ល្វង សុខខេង | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងនីតិកម្មនៃអគ្គនាយកដ្ឋានកៅស៊ូ |
| ២០- | លោក | សុង ដារី | អនុប្រធានការិយាល័យបុគ្គលិកនៃនាយកដ្ឋានរដ្ឋបាលនិងនីតិកម្មនៃអគ្គនាយកដ្ឋានកៅស៊ូ |
| ២១- | លោក | អ៊ុច វ៉ាន់ណេត | អនុប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានរដ្ឋបាលនិងនីតិកម្មនៃអគ្គនាយកដ្ឋានកៅស៊ូ |
| ២២- | លោកស្រី | ឆិន ម៉ារ៉េន | អនុប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិនៃអគ្គនាយកដ្ឋានកៅស៊ូ |
| ២៣- | លោក | ស្រស់ ហ៊ាន់ | ប្រធានការិយាល័យផែនការ-គណនេយ្យនៃមន្ទីរកសិកម្មខេត្តព្រៃវែង |
| ២៤- | លោក | ឌី សំអាន | អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម |
| ២៥- | លោកស្រី | សាខន សុធានី | នាយិការងនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| ២៦- | លោក | សាយ ពុទ្ធា | ប្រធានការិយាល័យនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| ២៧- | លោក | ឈា សំអុល | ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| ២៨- | លោក | គាំ ម៉ែត | ប្រធានការិយាល័យរដ្ឋបាល-បុគ្គលិកនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| ២៩- | លោក | យឹម ណាន | អនុប្រធានមន្ទីរកសិកម្មខេត្តកំពង់ស្ពឺ |
| ៣០- | លោក | លឹម គីមឡុង | ប្រធានការិយាល័យរដ្ឋបាល បុគ្គលិកនៃមន្ទីរកសិកម្មខេត្តកំពង់ស្ពឺ |
| ៣១- | លោក | រិត សំរ៉េត | ប្រធានការិយាល័យកសិកម្មស្រុកថ្ពងនៃមន្ទីរកសិកម្មខេត្តកំពង់ស្ពឺ |
| ៣២- | លោក | ងួន សុធី | ប្រធានការិយាល័យរដ្ឋបាល បុគ្គលិកនៃនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ |
| ៣៣- | លោក | ណុប ចំរើន | អនុប្រធានការិយាល័យគណនេយ្យនៃនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ |
| ៣៤- | លោក | លៀង សេង | អនុប្រធានមន្ទីរកសិកម្មខេត្តក្រចេះ |
| ៣៥- | លោក | អោគ សុទ្ធារិទ្ធ | អនុប្រធានមន្ទីរកសិកម្មខេត្តក្រចេះ |
| ៣៦- | លោក | ម៉ៅ វិចិត្រ | អនុប្រធានមន្ទីរកសិកម្មខេត្តក្រចេះ |
| ៣៧- | លោក | ហេង គីឆេង | ប្រធានការិយាល័យផែនការ-គណនេយ្យនៃមន្ទីរកសិកម្មខេត្តក្រចេះ |
| ៣៨- | លោក | អ៊ីវ សុខសាន្ត | អធិការនៃអគ្គាធិការដ្ឋាន |
| ៣៩- | លោកស្រី | សុន សុខុម | អនុប្រធានការិយាល័យអធិការកិច្ចកិច្ចការទូទៅនៃអគ្គាធិការដ្ឋាន |
| ៤០- | លោក | ម៉ៅ សុវឌ្ឍន៍ | អនុប្រធានការិយាល័យទទួលពាក្យបណ្តឹងនៃអគ្គាធិការដ្ឋាន |
| ៤១- | លោក | ចាន់ ហេង | ប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានកិច្ចការរដ្ឋបាល |
| ៤២- | លោកស្រី | អ៊ួង អេង | អនុប្រធានការិយាល័យតំកល់ឯកសារនៃនាយកដ្ឋានកិច្ចការរដ្ឋបាល |
| ៤៣- | លោក | វង្ស ណារិទ្ធ | អនុប្រធានការិយាល័យសន្តិសុខនៃនាយកដ្ឋានកិច្ចការរដ្ឋបាល |
| ៤៤- | លោក | ឃឹម ខុន | មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានកិច្ចការរដ្ឋបាល |
| ៤៥- | លោកស្រី | នួន ផល្លា | មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានកិច្ចការរដ្ឋបាល |
| ៤៦- | លោក | អ៊ុច ប៊ុន្ថា | មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស |
| ៤៧- | លោក | ផល ហាត | អនុប្រធានទទួលបន្ទុករួមការិយាល័យរដ្ឋបាល-បុគ្គលិកនៃមន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង |
| ៤៨- | លោក | គីម សាវឿន | ប្រធានមន្ទីរកសិកម្មខេត្តកំពង់ចាម |
| ៤៩- | លោក | ឆេង ណារ៉េត | អនុប្រធានមន្ទីរកសិកម្មខេត្តកំពង់ចាម |
| ៥០- | លោក | ស៊ឹម ថាវីរៈ | អនុប្រធានមន្ទីរកសិកម្មខេត្តកំពង់ចាម |
| ៥១- | លោក | ម៉ៅ វណ្ណាថន | ប្រធានស្តីទីការិយាល័យផែនការគណនេយ្យនៃមន្ទីរកសិកម្មខេត្តកំពង់ចាម |
| ៥២- | លោក | ពឹង ទ្រីដា | ប្រធានមន្ទីរកសិកម្មខេត្តព្រះវិហារ |

| | | | |
|---|---|---|---|
| ៥៣- | លោក | ស្រ៊ុន បូរិន្ទ | អនុប្រធានមន្ទីរកសិកម្មខេត្តព្រះវិហារ |
| ៥៤- | លោក | ហ៊ល ដារុន | នាយករងវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| ៥៥- | លោក | អ៊ុង សេរីវុឌ្ឍ | មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| ៥៦- | លោកស្រី | វ៉ា សុផល | មន្ត្រីការិយាល័យរដ្ឋបាលនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| ៥៧- | លោក | គា ផា | ប្រធានការិយាល័យផ្សព្វផ្សាយបច្ចេកទេសនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| ៥៨- | លោក | ម៉ៅ ដារុធ | អនុប្រធានទទួលបន្ទុករួមការិយាល័យបសុព្យាបាលនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| ៥៩- | លោក | ប៊ុត ត្រឹក | មន្ត្រីការិយាល័យផលិតកម្មនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| ៦០- | លោកស្រី | ឆ្លួយ មុំ | អនុប្រធានការិយាល័យរោគរាតត្បាតនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| ៦១- | លោក | អ៊ុច សាវន | អនុប្រធានមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ |
| ៦២- | លោក | ហ៊ុយ ទូច | ប្រធានការិយាល័យផលិតកម្មនិងបសុព្យាបាលនៃមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ |
| ៦៣- | លោក | រុន សុផាន់ណារ៉ា | ប្រធានការិយាល័យក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មនៃមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ |
| ៦៤- | លោក | ជង់ ប៊ុនសួរ | ប្រធានការិយាល័យកសិកម្មស្រុកមង្គលបូរីនៃមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ |
| ៦៥- | លោក | ឈុន សុខផល្លា | មន្ត្រីនាយកដ្ឋានកិច្ចការរដ្ឋបាលនិងនីតិកម្មនៃរដ្ឋបាលជលផល |
| ៦៦- | លោក | សុខ ឡុង | អនុប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិនៃរដ្ឋបាលជលផល |
| ៦៧- | លោកស្រី | ឌុច សុធារី | អនុប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិនៃរដ្ឋបាលជលផល |
| ៦៨- | លោកស្រី | ហ្លួត គន្ធាចិន្តា | អនុប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ នៃន.ផ.សនៃរដ្ឋបាលជលផល |
| ៦៩- | លោក | លី គួង | ប្រធានការិយាល័យរដ្ឋបាលនៃន.ក.ជនៃរដ្ឋបាលជលផល |
| ៧០- | លោកស្រី | ណាយ ប៊ុក | អនុការិយាល័យដែននេសាទ ផែនទីនិងព័ត៌មានភូមិសាស្ត្រ នៃន.ក.ជនៃរដ្ឋបាលជលផល |
| ៧១- | លោក | ជី គីម | មន្ត្រីការិយាល័យនេសាទសមុទ្រនៃន.ក.ជនៃរដ្ឋបាលជលផល |
| ៧២- | លោកស្រី | ស្រេង ផុនទី | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្មនៃរដ្ឋបាលជលផល |
| ៧៣- | លោកស្រី | ឈី សាវរី | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្មនៃរដ្ឋបាលជលផល |
| ៧៤- | លោក | ឈ្លួន ចំណាន | អនុប្រធាននាយកដ្ឋានបច្ចេកវិទ្យាកែច្នៃនិងគុណភាពនៃរដ្ឋបាលជលផល |
| ៧៥- | លោក | ស្វ ណាម | ប្រធាន វ.ស.អ.ទ.សនៃរដ្ឋបាលជលផល |
| ៧៦- | លោក | គង់ ពុទ្ធារិទ្ធ | នាយខណ្ឌរដ្ឋបាលជលផលកំពង់ចាមនៃរដ្ឋបាលជលផល |
| ៧៧- | លោក | ស៊ុន សុធី | នាយរងអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាបនៃរដ្ឋបាលជលផល |
| ៧៨- | លោក | ហុង ហ៊ី | នាយអធិការ.របជផខាងត្បូងងបឹងទន្លេសាបនៃរដ្ឋបាលជលផល |
| ៧៩- | លោក | មាឃ សឿង | នាយរងអធិការ.របជផខាងត្បូងបឹងទន្លេសាបនៃរដ្ឋបាលជលផល |
| ៨០- | លោក | ប្រាក់ ធុយ | នាយរងអធិការ.របជផខាងត្បូងបឹងទន្លេសាបនៃរដ្ឋបាលជលផល |
| ៨១- | លោក | ជួង សុភា | នាយខណ្ឌរដ្ឋបាលជលផលបាត់ដំបងនៃរដ្ឋបាលជលផល |
| ៨២- | លោក | ស្លួង សុផល | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រនៃរដ្ឋបាលជលផល |
| ៨៣- | លោក | ឈុត ឡាយអ៊ីន | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រនៃរដ្ឋបាលជលផល |
| ៨៤- | លោក | លោក ខ្លង សំអាត | នាយខណ្ឌរដ្ឋបាលជលផលកំពង់សោមនៃរដ្ឋបាលជលផល |
| ៨៥- | លោក | ឡាង គីរី | នាយខណ្ឌរដ្ឋបាលជលផលកោះកុងនៃរដ្ឋបាលជលផល |
| ៨៦- | លោក | ហាម អឿន | ប្រធានការិយាល័យផែនការ គណនេយ្យនៃមន្ទីរកសិកម្មខេត្តប៉ៃលិន |
| ៨៧- | លោក | ប៉ក់ ចាន់បូរា | អនុប្រធានការិយាល័យសវនកម្មទី២នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៨៨- | លោក | លី ស៊ិន | អនុប្រធានការិយាល័យរដ្ឋបាល និងសេវាកម្មទូទៅនៃរដ្ឋបាលព្រៃឈើ |
| ៨៩- | លោក | ស្លួន សុវណ្ណ | អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្មនៃរដ្ឋបាលព្រៃឈើ |
| ៩០- | លោក | ហែម ច័ន្ទរិទ្ធី | ប្រធានបណ្តុះបណ្តាលវិស័យព្រៃឈើ និងសត្វព្រៃនៃរដ្ឋបាលព្រៃឈើ |

| | | | |
|---|---|---|---|
| ៩១- | លោក | ប្រាក់ ណូម៉ា | នាយខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាមនៃរដ្ឋបាលព្រៃឈើ |
| ៩២- | លោក | គីម ណារ៉ា | នាយ ផ្នែក រដ្ឋបាលព្រៃឈើកំពង់ចាមត្រើយម្ខាងនៃរដ្ឋបាលព្រៃឈើ |
| ៩៣- | លោក | ហេង ចំរើន | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៩៤- | លោក | ឯក សុភាព | ព្រឹទ្ធបុរសរងមហាវិទ្យាល័យកសិឧស្សាហកម្មនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៩៥- | លោក | ម៉ៅ សាប៊ីណា | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្មនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៩៦- | លោក | ឡៅ លីតួ | នាយករងសាលាក្រោយឧត្តមនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៩៧- | លោក | សាន សុគន្ធា | នាយករងសាលាក្រោយឧត្តមនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៩៨- | លោកស្រី | កង ក្រឹស្នា | ព្រឹទ្ធបុរសមហាវិទ្យាល័យបច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្មនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៩៩- | លោកស្រី | វុន វារី | ព្រឹទ្ធបុរសរងមហាវិទ្យាល័យបច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្មនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ១០០- | លោក | ជា គីមហេង | អនុប្រធានន/ដ្ឋានរដ្ឋបាល ផែនការគណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិនៃអគ្គនាយកដ្ឋានកសិកម្ម |
| ១០១- | លោក | ប៉ែន នៅ | ប្រធានការិ/បច្ចេកវិទ្យាកសិកម្មមុនពេលប្រមូលផល ន/ដ្ឋានគ្រឿងយន្តកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម |
| ១០២- | លោក | ប៉ែន វុទ្ធី | ជំនួយការប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម |
| ១០៣- | លោក | ស៊ឹង ប៊ុនធី | ប្រធានកសិដ្ឋានចំការលើនៃអគ្គនាយកដ្ឋានកសិកម្ម |
| ១០៤- | លោក | ងួន សុភាព | ប្រធានដេប៉ាតឺម៉ង់ដំណាំកៅស៊ូនៃសាលាជាតិកសិកម្មកំពង់ចាម |
| ១០៥- | លោក | ថាត់ សុវណ្ណរិទ្ធ | ប្រធានដេប៉ាតឺម៉ង់វិទ្យា.ជលផលនៃសាលាជាតិកសិកម្មកំពង់ចាម |
| ១០៦- | លោកស្រី | គិត សុខធីម | ប្រធានដេប៉ាតឺម៉ង់វិទ្យា.វេជ្ជសាស្ត្រសត្វនៃសាលាជាតិកសិកម្មកំពង់ចាម |
| ១០៧- | លោកស្រី | យក់ ពិសី | ប្រធានមជ្ឈមណ្ឌលឯកសារនៃសាលាជាតិកសិកម្មកំពង់ចាម |
| ១០៨- | លោក | អឿន ឌីន | ប្រធានដេប៉ាតឺម៉ង់ឆ្នាំសិក្សាមូលដ្ឋាននៃសាលាជាតិកសិកម្មកំពង់ចាម |
| ១០៩- | លោក | ឡី គីមហេង | ប្រធានដេប៉ាតឺម៉ង់សេដ្ឋកិច្ចកសិកម្មនៃសាលាជាតិកសិកម្មកំពង់ចាម |

**ខ-មេដាយសុវត្ថារា ថ្នាក់ សេនា**

| | | | |
|---|---|---|---|
| ១- | លោក | តូ ជីពេជ្រ | អនុប្រធានការិយាល័យរដ្ឋបាល-បុគ្គលិកនៃមន្ទីរកសិកម្មខេត្តពោធិ៍សាត់ |
| ២- | លោក | ពូន សុខុន | មន្ត្រីការិយាល័យរដ្ឋបាល-បុគ្គលិកនៃមន្ទីរកសិកម្មខេត្តពោធិ៍សាត់ |
| ៣- | លោក | ម៉ៃ រតនា | អនុប្រធានការិយាល័យផលិតកម្មនិងបសុព្យាបាលនៃមន្ទីរកសិកម្មខេត្តស្ទឹងត្រែង |
| ៤- | លោក | ប៊ុន វាសនា | អនុប្រធានការិយាល័យផលិតកម្មនិងបសុព្យាបាលនៃមន្ទីរកសិកម្មខេត្តស្ទឹងត្រែង |
| ៥- | លោក | សួន វិន | អនុប្រធានការិយាល័យកសិកម្មស្រុកថាឡាបរិវ៉ាត់នៃមន្ទីរកសិកម្មខេត្តស្ទឹងត្រែង |
| ៦- | លោក | ផល្លី ចាន់ធី | អនុប្រធានការិយាល័យកសិកម្មស្រុកសេសាននៃមន្ទីរកសិកម្មខេត្តស្ទឹងត្រែង |
| ៧- | លោក | អ៊ុក ចាន់ថន | ប្រធានការិយាល័យកសិកម្មស្រុកសៀមបូកនៃមន្ទីរកសិកម្មខេត្តស្ទឹងត្រែង |
| ៨- | លោក | សៀង ម៉េងហ៊ង | ប្រធានការិយាល័យផលិតកម្មនិងបសុព្យាបាលនៃមន្ទីរកសិកម្មខេត្តស្ទឹងត្រែង |
| ៩- | លោក | ដួង ម៉ាឡាន់ | មន្ត្រីការិយាល័យផែនការ-គណនេយ្យនៃមន្ទីរកសិកម្មខេត្តស្ទឹងត្រែង |
| ១០- | លោក | ឡា ពុទ្ធារី | ប្រធានការិយាល័យក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មនៃមន្ទីរកសិកម្មខេត្តស្ទឹងត្រែង |
| ១១- | លោក | ម៉ែន វណ្ណៈ | ប្រធានការិយាល័យនីតិកម្មកសិកម្មនៃមន្ទីរកសិកម្មខេត្តកែប |
| ១២- | លោក | ប៉ា គីមអាង | ប្រធានការិយាល័យកសិ ឧស្សាហកម្មនៃមន្ទីរកសិកម្មខេត្តកែប |
| ១៣- | លោក | ណុប សារិន | អនុប្រធានការិយាល័យផ្សព្វផ្សាយកសិកម្មនៃមន្ទីរកសិកម្មខេត្តកែប |
| ១៤- | លោកស្រី | សុខ ចិន្តា | អនុប្រធានការិយាល័យរដ្ឋបាល-បុគ្គលិកនៃមន្ទីរកសិកម្មខេត្តកែប |
| ១៥- | លោក | ឡុង ផន | អនុប្រធានមន្ទីរកសិកម្មនៃមន្ទីរកសិកម្មខេត្តបាត់ដំបង |
| ១៦- | លោកស្រី | យ៉ឹម សារ៉ាត់ | អនុប្រធានការិយាល័យផ្សព្វផ្សាយនៃមន្ទីរកសិកម្មខេត្តបាត់ដំបង |
| ១៧- | លោក | គា ឈុន | អនុប្រធានការិយាល័យផ្សព្វផ្សាយនៃមន្ទីរកសិកម្មខេត្តបាត់ដំបង |
| ១៨- | លោក | គង់ ចន្ថា | អនុប្រធានមន្ទីរកសិកម្មខេត្តសៀមរាប |

| | | | |
|---|---|---|---|
| ១៩- | លោកស្រី | សរ រីណា | អនុប្រធានមន្ទីរកសិកម្មខេត្តសៀមរាប |
| ២០- | លោក | ស៊ឹម ធរដ្ឋ | អនុប្រធានការិយាល័យផលិតកម្មនិងបសុព្យាបាលនៃមន្ទីរកសិកម្មខេត្តសៀមរាប |
| ២១- | លោក | ម៉ាន់ ថែម | ប្រធានការិយាល័យកសិកម្មស្រុកពួកនៃមន្ទីរកសិកម្មខេត្តសៀមរាប |
| ២២- | លោក | តែ គីមខ្លង | ប្រធានការិយាល័យកសិកម្មស្រុកក្រឡាញ់នៃមន្ទីរកសិកម្មខេត្តសៀមរាប |
| ២៣- | លោកស្រី | ឡូ សុខា | អនុប្រធានការិយាល័យសហទ្វេភាគីនិងពហុភាគីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ២៤- | លោក | មោង ម៉ាន់ | ប្រធានការិយាល័យផលិតកម្មនិងបសុព្យាបាលនៃមន្ទីរកសិកម្មខេត្តរតនគិរី |
| ២៥- | លោក | ធីវ វណ្ណធីរ | ប្រធានមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ២៦- | លោក | ឈួ គីមធី | អនុប្រធានការិយាល័យផលិតកម្មនិងបសុព្យាបាលនៃមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ២៧- | លោក | ជៀប រតនា | អនុប្រធានការិយាល័យផលិតកម្មនិងបសុព្យាបាលនៃមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ២៨- | លោក | ស៊ុន តាំ | ប្រធានការិយាល័យស្រុកប្រាសាទសំបូរនៃមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ២៩- | លោក | ទឹម សំអុល | ប្រធានការិយាល័យស្រុកកំពង់ស្វាយនៃមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ៣០- | លោក | ហុង នន | មន្ត្រីការិយាល័យគ្រឿងយន្តកសិកម្មនៃមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ៣១- | លោក | ហែម ប៊ុនថេង | មន្ត្រីការិយាល័យផែនការ-គណនេយ្យនៃមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ៣២- | លោក | ហោ សម្បត្តិ | មន្ត្រីការិយាល័យផលិតកម្មនិងបសុព្យាបាលនៃមន្ទីរកសិកម្មខេត្តកំពង់ធំ |
| ៣៣- | លោក | ប៉ែន សក្តិពិសិដ្ឋ | អនុប្រធានការិយាល័យនីតិកម្មកសិកម្មនៃមន្ទីរកសិកម្មខេត្តឧត្តរមានជ័យ |
| ៣៤- | លោក | សុខ វឿ | អនុប្រធានការិយាល័យកសិកម្មស្រុកត្រពាំងប្រាសាទនៃមន្ទីរកសិកម្មខេត្តឧត្តរមានជ័យ |
| ៣៥- | លោក | ញ៉ែម បូផល | អនុប្រធានការិយាល័យផ្សព្វផ្សាយកសិកម្មនៃមន្ទីរកសិកម្មខេត្តព្រះសីហនុ |
| ៣៦- | លោក | អួន សុវណ្ណ | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងនីតិកម្មនៃអគ្គនាយកដ្ឋានកៅស៊ូ |
| ៣៧- | លោក | ឃុន កក្កដា | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូនៃអគ្គនាយកដ្ឋានកៅស៊ូ |
| ៣៨- | លោក | ឈៀក សារ៉ាន់ | មន្ត្រីនាយកដ្ឋានរដ្ឋបាលនិងនីតិកម្មនៃអគ្គនាយកដ្ឋានកៅស៊ូ |
| ៣៩- | លោក | សុខ ឃុន | មន្ត្រីនាយកដ្ឋានរដ្ឋបាលនិងនីតិកម្មនៃអគ្គនាយកដ្ឋានកៅស៊ូ |
| ៤០- | លោកស្រី | ហ៊ី សិទ្ធី | មន្ត្រីនាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិនៃអគ្គនាយកដ្ឋានកៅស៊ូ |
| ៤១- | លោកស្រី | ស ស៊ីមលីន | អនុប្រធានផែនការ-គណនេយ្យនៃមន្ទីរកសិកម្មខេត្តកណ្តាល |
- សិក្សាស្រាវជ្រាវអំពីស្ថានភាពសហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា ទាំងបរិមាណ និងទាំងទំហំដោយផ្អែកលើផលរបរ
- សិក្សាស្រាវជ្រាវអំពីស្ថានភាពនៃការអនុវត្តកាតព្វកិច្ចកាន់បញ្ជីគណនេយ្យដោយសហគ្រាសធុនតូច និងមធ្យម
- សិក្សាស្រាវជ្រាវអំពីស្ថានភាពទូទៅនៃមីក្រូសហគ្រាស និងសេចក្តីត្រូវការគំរូនៃការកត់ត្រាគណនេយ្យ និងគំរូរបាយការណ៍ហិរញ្ញវត្ថុសាមញ្ញ សម្រាប់ដាក់ឱ្យសហគ្រាសទាំងនោះអនុវត្ត
- ពិនិត្យលទ្ធភាពរៀបចំ និងបង្កើតនូវគំរូនៃការកត់ត្រាគណនេយ្យ និងគំរូរបាយការណ៍ហិរញ្ញវត្ថុសាមញ្ញ ដើម្បីដាក់ឱ្យសហគ្រាសទាំងនោះអនុវត្ត
- សិក្សាស្រាវជ្រាវអំពីលទ្ធភាពរបស់សហគ្រាសធុនតូច និងមធ្យម ក្នុងការបោះផ្សាយលក់មូលបត្រជាសាធារណៈស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យ និងសម្រេចលើលទ្ធផលពីការសិក្សាស្រាវជ្រាវនានា រួចរៀបចំជារបាយការណ៍ដែលទទួលបានពីការសិក្សាស្រាវជ្រាវ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងសុំការណែនាំ និងអនុសាសន៍
- អនុវត្តការងារពាក់ព័ន្ធផ្សេងទៀតទៅតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ២.-**

ត្រូវបានតែងតាំង **ឯកឧត្តម លោក លោកស្រី** ក្នុងក្រុមការងារកិច្ចការគណនេយ្យ ពន្ធដារ និងទីផ្សារមូលបត្រ ដែលមានសមាសភាពដូចខាងក្រោមនេះ÷

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **ទី តាឃី** | រដ្ឋលេខាធិការ ស.ហ.វ និងជាប្រធាន ក.ជ.គ | ប្រធាន |
| ២. | ឯកឧត្តម | **ទ៉ាន់ ពុទ្ធិពល** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធាន |
| ៣. | ឯកឧត្តម | **សុខ ដារ៉ា** | អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា | អនុប្រធាន |
| ៤. | លោក | **ខូយ គីមលេង** | ប្រធាន វ.គ.ស.ក | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៥. | លោក | **សៀង ស៊ីថា** | អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៦. | បណ្ឌិត | **សំ យន្នី** | ទីប្រឹក្សាអមក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក |
| ៧. | លោក | **ខេស៊ី ឆារណេត** | ទីប្រឹក្សាអមក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក |
| ៨. | លោក | **ទ៉ែ ហ៊ុយ** | សមាជិក វ.គ.ស.ក | សមាជិក |
| ៩. | លោក | **មាស សក្តិសម** | សមាជិក វ.គ.ស.ក | សមាជិក |
| ១០. | លោក | **ម៉ូ ថារិន** | លេខាធិការរង ក.ជ.គ | សមាជិក |
| ១១. | លោក | **សេង តុលា** | លេខាធិការរង ក.ជ.គ | សមាជិក |
| ១២. | លោក | **ឥន្ទ សុខាទុង** | ប្រធានការិយាល័យសវនកម្មទី១ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៣. | លោកស្រី | **នាន បូនី** | ប្រធានការិយាល័យត្រួតពិនិត្យកិច្ចការគណនេយ្យ នៃគណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ១៤. | លោកស្រី | **ទូច ចន្ទណ្ណារ៉ា** | សមាជិក វ.គ.ស.ក | សមាជិក |
| ១៥. | លោក | **ខេន ផារត** | មន្ត្រីបច្ចេកទេស ក.ជ.គ | សមាជិកនិងជាលេខាធិការ។ |

**ប្រការ ៣.-**

សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ពេលប្រធានអវត្តមាន ក្រុមការងារអាចប្រជុំក្រោមការដឹកនាំរបស់តំណាងដែលជាអនុប្រធានណាម្នាក់ ក្នុងនាមជាប្រធានស្តីទី តាមការប្រគល់សិទ្ធិរបស់ប្រធាន ដើម្បីធានានិរន្តភាពនៃក្រុមការងារ។

**ប្រការ ៤.-**

កិច្ចប្រជុំរបស់ក្រុមការងារនេះ អាចប្រព្រឹត្តិទៅបានលុះត្រាតែមានចំនួនកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិកក្រុមការងារ ប៉ុន្តែរាល់ការសម្រេចនៃកិច្ចប្រជុំត្រូវយកសម្លេងភាគច្រើនដាច់ខាត ទើបអាចយកជាការបាន។ ក្នុងករណីមានបែកសម្លេងជាពីរស្មើគ្នា សម្លេងរបស់ប្រធានអង្គប្រជុំមានឧត្តមានុភាព។

**ប្រការ ៥.-**

ធនធាន និងថវិកាសម្រាប់ចំណាយលើកិច្ចដំណើរការរបស់ក្រុមការងារនេះ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់កញ្ចប់ថវិការបស់ក្រុមប្រឹក្សាជាតិគណនេយ្យក្នុងក្របខ័ណ្ឌឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB),

កញ្ចប់ថវិកាជាតិ ឬប្រភពផ្សេងទៀត។ ក្រុមការងារ ទទួលបានប្រាក់បំណាច់ប្រជុំ ដូចប្រាក់បំណាច់កិច្ចប្រជុំក្រុមប្រឹក្សាជាតិគណនេយ្យដែរ។

**ប្រការ ៦.-**

ក្រុមការងារ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការ អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**<u>ចម្លងជូន:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៧
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣២១ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក. ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក. ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១ ...

លេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855 23 724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញសេចក្តីជូនដំណឹងលេខ៦៨០ សជណ. ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខ ២៩៨ សហវ. ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥
- យោងតាមការសម្រេចក្នុងវេទិការាជរដ្ឋាភិបាលនិងផ្នែកឯកជនលើកទី១៧ កាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៤ ដែលជាការប្រជុំគណៈរដ្ឋមន្ត្រីបើកទូលាយ

**សម្រេច ÷**

**ប្រការ ១ .- គោលបំណង**

ប្រកាសនេះមានគោលបំណង សម្រួលយន្តការអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញឬសេវាមួយចំនួន ដើម្បីជម្រុញនិងលើកកំពស់សកម្មភាពនាំចេញដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២ .- វិសាលភាពអនុវត្ត**

១- ការដាក់ចេញនូវយន្តការអនុគ្រោះមួយចំនួនក្នុងការអនុវត្តន៍អាករលើតម្លៃបន្ថែម ដូចមានចែងក្នុងប្រកាសនេះ អនុវត្តចំពោះតែ ឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាដោយផ្ទាល់សម្រាប់បម្រើឱ្យការនាំចេញរបស់ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរ និងកាបូបដៃ និងឧស្សាហកម្មផលិតមួក។

២- ទំនិញនិងសេវាដែលបានផ្គត់ផ្គង់ផ្ទាល់ដោយឧស្សាហកម្មគាំទ្រឬអ្នកចុះកិច្ចសន្យា ដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ កម្រិតត្រឹមតែ ÷

- សំបកវេចខ្ចប់
- សរសៃអំបោះ ក្រណាត់ ខ្សែរ ខ្សែូត ទិកក់ព្យួរ ដង្កៀបសម្លៀកបំពាក់ និងគ្រឿងភ្ជាប់នឹងសម្លៀកបំពាក់ ស្បែកជើង កាបូប និងមួក
- សេវាបោកគក់ ជ្រលក់ បោះពុម្ពលើក្រណាត់ឬសម្លៀកបំពាក់ ដេរ ប៉ាក់។

**ប្រការ ៣ .- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ÷

១- ពាក្យ " ឧស្សាហកម្មគាំទ្រ " សំដៅដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងមាត្រា ២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើការផ្គត់ផ្គង់ដោយផ្ទាល់នូវទំនិញឬសេវារបស់ខ្លួន សម្រាប់បម្រើឱ្យការនាំចេញរបស់ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក។

២- ពាក្យ "អ្នកចុះកិច្ចសន្យា" សំដៅដល់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គង់ដោយផ្ទាល់នូវទំនិញឬសេវារបស់ខ្លួនចាប់ពី ៨០% ឡើងទៅ សម្រាប់បម្រើឱ្យការនាំចេញរបស់ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក។

៣- ពាក្យ "ធាតុចូលផលិតកម្ម " សំដៅដល់ផលិតផលរួមមានវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសម្ភារៈបន្ទាប់បន្សំសម្រាប់បម្រើផលិតកម្ម ដែលត្រូវបានបំប្លែងឬត្រូវបានប្រើប្រាស់យ៉ាងពេញលេញនៅក្នុងកិច្ចដំណើរការផលិតកម្មរបស់ឧស្សាហកម្មគាំទ្រ។

៤- ពាក្យ " សម្ភារៈបរិក្ខារផលិតកម្ម " សំដៅដល់គ្រឿងម៉ាស៊ីន ឧបករណ៍ ដែលបានប្រើប្រាស់ជាមូលដ្ឋានសំខាន់ក្នុងការបំប្លែងធាតុចូលផលិតកម្មរបស់ឧស្សាហកម្មគាំទ្រ។

**ប្រការ ៤ .- យន្តការអនុគ្រោះអាករលើតម្លៃបន្ថែម**

១- អាករលើតម្លៃបន្ថែមអនុវត្តចំពោះឧស្សាហកម្មគាំទ្រ ត្រូវបានអនុគ្រោះដូចខាងក្រោម ÷

ក- អាករលើធាតុចូល ÷

- អាករលើតម្លៃបន្ថែមលើការនាំចូលនូវ ធាតុចូលផលិតកម្ម និងសម្ភារៈបរិក្ខារផលិតកម្ម សម្រាប់ផលិតបម្រើឱ្យការផ្គត់ផ្គង់ដោយផ្ទាល់ដល់ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក ត្រូវបានចាត់ទុកជាបន្ទុករបស់រដ្ឋ។ ក្នុងករណីមានបំណងលក់ធាតុចូលផលិតកម្មឬ/និងសម្ភារៈបរិក្ខារផលិតកម្មឧស្សាហកម្មគាំទ្រត្រូវជូនដំណឹងជាមុនដល់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- រាល់ការទិញទំនិញឬសេវាក្នុងស្រុកត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា ១០ ភាគរយ។

ខ- អាករលើធាតុចេញ ÷

- ការផ្គត់ផ្គង់ទំនិញឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រាសូន្យភាគរយ
- ការផ្គត់ផ្គង់ទំនិញឬសេវា ទៅទីផ្សារក្នុងស្រុកត្រូវជាប់អាករលើតម្លៃបន្ថែម តាមអត្រា ១០ ភាគរយ និងត្រូវបង់ពន្ធគយនិងអាករតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

២- អាករលើតម្លៃបន្ថែមអនុវត្តចំពោះអ្នកចុះកិច្ចសន្យា ត្រូវបានអនុគ្រោះដូចខាងក្រោម ÷

ក- អាករលើធាតុចូល ÷

- ការនាំចូលឬការទិញក្នុងស្រុកនូវធាតុចូលផលិតកម្មនិងសម្ភារៈបរិក្ខារផលិតកម្មឬសេវានានា ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា ១០ ភាគរយ និងពន្ធអាករដទៃទៀតតាមច្បាប់ជាធរមាន។ អ្នកចុះកិច្ចសន្យាអាចទទួលការផ្គត់ផ្គង់ផ្ទាល់នូវធាតុចូលផលិតកម្មពី ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក ដែលជាភាគីនៃកិច្ចសន្យា។

ខ- អាករលើធាតុចេញ ÷

- ការផ្គត់ផ្គង់ទំនិញឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រាសូន្យភាគរយ
- ការផ្គត់ផ្គង់ទំនិញឬសេវា ទៅទីផ្សារក្នុងស្រុកត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា ១០ ភាគរយ។
- ក្នុងករណីដែលអ្នកចុះកិច្ចសន្យាទទួលការផ្គត់ផ្គង់ធាតុចូលផលិតកម្មពី ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក មិនបានធ្វើការផ្គត់ផ្គង់គ្រប់ចំនួនតាមកិច្ចសន្យានិងបទដ្ឋានបច្ចេកទេសផលិតកម្ម អ្នកចុះ

កិច្ចសន្យាត្រូវបង់អាករលើតម្លៃបន្ថែមលើចំណែកដែលមិនបានផ្គត់ផ្គង់នោះ ហើយឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិត ស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក ត្រូវបង់ពន្ធគយនិងអាករលើធាតុចូលផលិតកម្មតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

៣- ការគណនាប្រាក់អាករលើតម្លៃបន្ថែមត្រូវបង់ ឥណទានអាករយោងទៅមុខ ឬស្នើសុំបង្វិលសង ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃជំពូកទី៦ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម លេខ១១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៩ ដែលបានធ្វើវិសោធនកម្មដោយអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១។

**ប្រការ ៥ .- ការស្នើសុំការអនុគ្រោះអាករលើតម្លៃបន្ថែម**

អ្នកចុះកិច្ចសន្យាត្រូវដាក់ពាក្យស្នើសុំទៅអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមទម្រង់ដែលបានកំណត់ ដើម្បីទទួលបាននូវការអនុគ្រោះដូចមានចែងក្នុងប្រការ៤ ខាងលើ សម្រាប់រយៈពេលមិនលើសពីមួយឆ្នាំក្នុងមួយលើកៗ។

**ប្រការ ៦ .- ភារកិច្ចរបស់ឧស្សាហកម្មគាំទ្រនិងអ្នកចុះកិច្ចសន្យា**

១- ឧស្សាហកម្មគាំទ្រនិងអ្នកចុះកិច្ចសន្យា ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម ÷

ក- ឧស្សាហកម្មគាំទ្រ ត្រូវផ្តល់ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ជារៀងរាល់ខែនូវរបាយការណ៍ស្តីពីបរិមាណ សន្និធិ បញ្ចូល បញ្ចេញ នូវវត្ថុធាតុដើមនិងទំនិញ តាមគំរូភ្ជាប់ជាមួយនឹងប្រកាសនេះ។

ខ- ឧស្សាហកម្មគាំទ្រនិងអ្នកចុះកិច្ចសន្យាត្រូវភ្ជាប់ច្បាប់ចម្លងនៃកិច្ចសន្យាស្តីពីការផ្គត់ផ្គង់ដល់ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក ជាមួយនឹងលិខិតប្រកាសសារពើពន្ធដែលត្រូវដាក់ជូនអគ្គនាយកដ្ឋានពន្ធដារនៅខែបន្ទាប់ពីខែដែលបានចុះកិច្ចសន្យា។

ខ- រៀងរាល់ពេលផ្គត់ផ្គង់ទំនិញឬសេវា ឧស្សាហកម្មគាំទ្រឬអ្នកចុះកិច្ចសន្យា ត្រូវចេញវិក្កយបត្រអាករឱ្យទៅឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក ដោយគិតអាករលើតម្លៃបន្ថែមតាមអត្រាសូន្យភាគរយ។

២- ក្នុងករណីមិនបានបំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃប្រការ៣ ឬ/និង មិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃប្រការនេះ ការអនុគ្រោះដូចមានចែងក្នុងប្រការ៤ នឹងត្រូវដកហូត។

៣- រៀងរាល់ពេលទទួលការផ្គត់ផ្គង់ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក ត្រូវអោនកាតព្វកិច្ចចេញលិខិតធានាអំពីការនាំចេញទំនិញឬសេវាឱ្យទៅឧស្សាហកម្មគាំទ្រឬអ្នកចុះកិច្ចសន្យា ដូចមានគម្រូភ្ជាប់មកជាមួយនឹងប្រកាសនេះ។ ក្នុងករណីមិនបាននាំចេញនូវទំនិញឬសេវាដែលបានផ្គត់ផ្គង់ដោយឧស្សាហកម្មគាំទ្រឬអ្នកចុះកិច្ចសន្យា ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក ត្រូវទទួលខុសត្រូវបង់អាករលើតម្លៃបន្ថែម និងត្រូវបង់ពន្ធគយនិងអាកររួមទាំងទោសទណ្ឌទៅតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៧ .-**

ប្រកាសលេខ២៩៨សហវ. ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់ផលិតផលឬសេវា សម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង ត្រូវទុកជានិរាករណ៍។

**ប្រការ ៨ .-**

នាយកខុទ្ទកាល័យ  អគ្គលេខាធិការ  នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ  ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ  ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ  និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ  ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

<u>**ចម្លងជូន**</u> ÷

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់ក្រសួង-ស្ថាប័ន
- សាលាខេត្ត-ក្រុង
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០១២...សហវ.ប្រក

# ប្រកាស

## ស្ដីពី

## ការអនុវត្តអាករលើតម្លៃបន្ថែម លើការនាំចូល និងការផ្គត់ផ្គង់ ទំនិញមួយចំនួន

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក. ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក. ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីអាករលើតម្លៃបន្ថែម
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១
- បានឃើញប្រកាសលេខ ៣០៣ សហវ.ពដ. ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១
- យោងតាមការសម្រេចក្នុងវេទិការាជរដ្ឋាភិបាលនិងផ្នែកឯកជនលើកទី១៧ កាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៤ ដែលជាការប្រជុំគណៈរដ្ឋមន្ត្រីបើកទូលាយ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef adm@yahoo.com

**សម្រេច ÷**

**ប្រការ ១ .- គោលបំណង**

ប្រកាសនេះមានគោលបំណង សម្រួលយន្តការអាករលើតម្លៃបន្ថែម ដើម្បីលើកកំពស់សកម្មភាពកសិកម្មដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២ .- ការអនុគ្រោះនូវអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ**

អាករលើតម្លៃបន្ថែមលើការនាំចូល និងការផ្គត់ផ្គង់ទំនិញមួយចំនួនដូចខាងក្រោមនេះ ត្រូវបានរដ្ឋទទួលបន្ទុក ÷

១- ជីគ្រប់ប្រភេទ រួមមាន ជីសំរាប់ប្រើក្នុងវិស័យកសិកម្មលើគ្រប់មុខដំណាំដែលផលិតដោយជាតិគីមី ជាតិសរីរាង្គ និងរ៉ែធម្មជាតិ។

២- ពូជដំណាំគ្រប់ប្រភេទ រួមមាន ÷

ក- គ្រាប់ពូជដំណាំគ្រប់ប្រភេទ

ខ- បំណែកពូជដំណាំគ្រប់ប្រភេទប្រើសំរាប់ការដាំដុះជា ដើម មើម ខ្នែង មែកសាក មែកផ្សាំ វល្លិ ។ល។

៣- បសុឱសថ រួមមាន ឱសថគ្រប់ប្រភេទប្រើប្រាស់តែលើសត្វគ្រប់ប្រភេទ សំរាប់ការទ្រទ្រង់សុខភាព ព្យាបាល ការពារ និងបង្កើនផលិតភាពរបស់សត្វ។

៤- ចំណីសត្វ និងចំណីបន្ថែម រួមមាន ÷

ក- ចំណីសត្វគ្រប់ប្រភេទសំរាប់ការទ្រទ្រង់ការលូតលាស់របស់សរីរាង្គសត្វ

ខ- ចំណីបន្ថែមគ្រប់ប្រភេទ វីតាមីន ឬអង្គធាតុរ៉ែផ្សេងៗទៀត សំរាប់ប្រើប្រាស់បន្ថែមលើចំណីសត្វ

គ- អង្កាម កន្ទក់ និងកម្ទេចចុងអង្ករ សម្រាប់ធ្វើចំណីសត្វ។

៥- ពូជសត្វគ្រប់ប្រភេទ រួមមាន ÷

ក- ពូជសត្វស្រុកគ្រប់ប្រភេទ

ខ- ពូជសត្វព្រៃគ្រប់ប្រភេទ ។

៦- គ្រឿងយន្ត និងឧបករណ៍កសិកម្មប្រភេទ ÷

ក- គោយន្តភ្ជួរ រាស់ និងបន្លាស់សំរាប់គ្រួសារ

ខ- ម៉ាស៊ីនកិនចំណីសត្វ

គ- ឧបករណ៍បណ្តុះគ្រាប់ពូជ ឬភ្ញាស់ស៊ុតសត្វ

ឃ- ពូបូមទឹកនៃម៉ាស៊ីនបូមទឹក ។

**ប្រការ ៣ .- ការកត់ត្រាចំណូលចំណាយ**

អាករលើតម្លៃបន្ថែមលើទំនិញដូចមានចែងក្នុងប្រការ ២ ខាងលើ ដែលរដ្ឋទទួលបន្ទុក ត្រូវបានកត់ត្រាបូកសរុបជាចំណូលនៃថវិកាប្រចាំខែ ហើយត្រូវបានកត់ត្រាក្នុងចំណាយជាអន្តរាគមន៍សេដ្ឋកិច្ចរបស់រដ្ឋ "ជំពូក៣០"។

**ប្រការ ៤ .-**

ប្រកាសលេខ ៣០៣ សហវ.ពដ. ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការនាំចូលនិងការផ្គត់ផ្គង់ទំនិញមួយចំនួន ត្រូវទុកជានិរាករណ៍។

**ប្រការ ៥ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៣ ឆ្នាំ ២០១៤

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន ÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់ក្រសួង-ស្ថាប័ន
- សាលាខេត្ត-ក្រុង
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០៤៧ MIH / 2014

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ២៩១៨/១៣គ.វ.ក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អេស-យ័ន (ខេមបូឌា) អឹភែរ៉ែល មេនូហ្វេកធឺរីង ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន អេស-យ័ន (ខេមបូឌា) អឹភែរ៉ែល មេនូហ្វេកធឺរីង (S-YUAN (CAMBODIA) APPAREL MANUFACTURING CO., LTD.) តំណាងដោយ លោក ZHANG CHUNWEI សញ្ជាតិចិន អាយុ៤៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខG20628429 ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ មានអាសយដ្ឋានបច្ចុប្បន្ន៖ No.305, Fu San New Village, Hai Men Town, Hai Jiang Su Province, China. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ផ្លាកឈ្មោះរោងចក្រ៖** *"រោងចក្រកាត់ដេរសម្លៀកបំពាក់ អេស-យ័ន (ខេមបូឌា) អឹភែរីល"*
**ទីតាំងរោងចក្រ៖** *"ភូមិព្រាំងពលទេព សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញ លក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៥៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤

**ន.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**ឡាយ ណាទីន**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"ា
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០៥៥ MIH / 2014

## ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៥៧៥អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ៥៥៦/១២ ម.ត.ស.ព ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន តូវ៉ា អ៊ិនដាសស្ទ្រី (ខេមបូឌា) ខមភេនី ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន តូវ៉ា អ៊ិនដាសស្ទ្រី (ខេមបូឌា) ខមភេនី (Towa Industry (Cambodia) Company Ltd.) តំណាងដោយ លោក CHEN, JUI-CHIEH សញ្ជាតិចិន(តៃវ៉ាន់) អាយុ៦២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 213796167 ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៥ មាន អាសយដ្ឋានបច្ចុប្បន្ន៖ Fl.6, No. 92, Da-Zhi Street, Taipei, Taiwan ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ឆ័ត្រ | ៣២៩០ |



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខៈ (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

**ផ្លាកឈ្មោះរោងចក្រ៖** *" រោងចក្រផលិតឥដ្ឋ តូរ៉ា អ៊ិនដាសស្ទ្រី (ខេមបូឌា) ខមភេនី "*
**ទីតាំងរោងចក្រ៖** *" តំបន់សេដ្ឋកិច្ចពិសេសមេនហាតធេនស្វាយរៀង សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងគម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចដូល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញនៅពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញ លក្ខខណ្ឌដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**ឡាយ ណាទីន**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តស្វាយរៀង

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០៥៥ MIH / 2014

## ប្រកាស

## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ២៥៨៥/១៣គ.វ.ក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អរៀន អ៊ិនធើណេសិនណល អេនធើប្រាយ (ខេមបូឌា) ហ្គាម៉ិន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន អរៀន អ៊ិនធើណេសិនណល អេនធើប្រាយ (ខេមបូឌា) ហ្គាម៉ិន (ORIENT INTERNATIONAL ENTERPRISE (CAMBODIA) GARMENT CO., LTD.) តំណាងដោយ លោក ZHANG DI សញ្ជាតិ ចិន អាយុ៤៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ P00955332 ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ មានអាសយដ្ឋាន បច្ចុប្បន្ន៖ 19F, Tower A, No.85 Loushanguan Road, Changning District, Shanghai City, P.R. China ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ( ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: ( ៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: ( ៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីម៉ែល: mih.smcabinet@gmail.com

**ផ្លាកឈ្មោះរោងចក្រ ៖** " *រោងចក្រកាត់ដេរសម្លៀកបំពាក់ អឿន អ៊ិនធើណេ សិនណាល អេនធើប្រាយ (ខេមបូឌា) ហ្គាមេន*

**ទីតាំងរោងចក្រ៖** " *ភូមិចំការរដ្ឋ ឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ* "

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញ លក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ នឹងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**ឡាយ ណារីន**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តកំពង់ស្ពឺ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"ឮ

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ